# ឧបករណ៍ឆ្លាតសម្រាប់អាជីវកម្ម

ការវិវត្តនៃបច្ចេកវិទ្យាបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវរបៀបដែលមនុស្សរស់នៅ, បំពេញការងារ, សិក្សារៀនសូត្រ និងទំនាក់ទំនងជាដើម ហើយជាក់ស្តែង ការប្រើប្រាស់នូវបច្ចេកវិទ្យា ដូចជា មីក្រូឈីប (Microchip), សែនស័រ (Sensor), បញ្ញាសិប្បនិម្មិត (Artificial Intelligence) និងទិន្នន័យធំ (Big Data) បានធ្វើឱ្យឧបករណ៍ប្រើប្រាស់នានា រួមមាន ទូរទស្សន៍, ឧបករណ៍បំពងសំឡេង, ទូរស័ព្ទ, កាមេរ៉ា និងអំពូលភ្លើងជាដើម មានសមត្ថភាពក្នុងការទំនាក់ទំនងជាមួយឧបករណ៍ផ្សេងទៀត និងអាចយល់ដឹងពីមជ្ឈដ្ឋានជុំវិញខ្លួន ព្រមទាំងអាចវិភាគទិន្នន័យ ដើម្បីព្យាករណ៍ពីតម្រូវការអ្នកប្រើប្រាស់ ដែលធ្វើឱ្យឧបករណ៍ទាំងនោះកាន់តែឆ្លាត។ យោងតាមគេហទំព័រ IGI Global **«ឧបករណ៍ឆ្លាត»** សំដៅដល់ឧបករណ៍អេឡិចត្រូនិក ដែលអាចភ្ជាប់ទៅកាន់ឧបករណ៍អេឡិចត្រូនិក ឬបណ្តាញផ្សេងទៀត តាមរយៈការតភ្ជាប់ឥតប្រើខ្សែ ដូចជា Bluetooth ឬអ៊ីនធឺណិត។

ឧបករណ៍ឆ្លាតមានលក្ខណសម្បត្តិសំខាន់ៗ ដូចជា៖

- **ស្វ័យប្រវត្តិកម្ម (Automation)៖** ឧបករណ៍ឆ្លាតអាចបំពេញការងារនានាបានដោយមិនត្រូវការការបញ្ជាពីអ្នកប្រើប្រាស់។ ជាឧទាហរណ៍ អំពូលភ្លើងឆ្លាតអាចបើកដោយស្វ័យប្រវត្តិនៅពេលមានមនុស្សឆ្លងកាត់ និងអាចបិទទៅវិញដោយស្វ័យប្រវត្តិនៅពេលគ្មានមនុស្ស។
- **ការបញ្ជាពីចម្ងាយ (Remote Control)៖** ឧបករណ៍ឆ្លាតក៏បានអនុញ្ញាតឱ្យមនុស្សធ្វើការបញ្ជាពីចម្ងាយបាន តាមរយៈទូរស័ព្ទ, កុំព្យូទ័រ ឬថេប្លេត។ ជាឧទាហរណ៍ ឧបករណ៍បើកទ្វារឆ្លាត (Smart Door Opener) អនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការបញ្ជាបើក ឬបិទទ្វារ ពីចម្ងាយ តាមរយៈទូរស័ព្ទដៃ។
- **ការយល់ដឹងពីបរិបទ (Context Awareness)៖** លក្ខណៈពិសេសចុងក្រោយរបស់ឧបករណ៍ឆ្លាត គឺវាមានសមត្ថភាពប្រមូល និងវិភាគទិន្នន័យដែលទទួលបានពីមជ្ឈដ្ឋានជុំវិញ។ ជាឧទាហរណ៍ នាឡិកាដៃឆ្លាតមានសមត្ថភាពប្រមូល និងវិភាគនូវទិន្នន័យទាក់ទងនឹងសីតុណ្ហភាព, ជីពចរ, ចង្វាក់បេះដូង និងទីតាំងជាដើម។

បច្ចុប្បន្ននេះ ការចេះទាញយកសក្តានុពលពីបច្ចេកវិទ្យាជាកត្តាមួយដែលអាចជួយឱ្យការធ្វើអាជីវកម្មទទួលបានជោគជ័យ ព្រោះបច្ចេកវិទ្យាពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយធ្វើឱ្យប្រសើរឡើងនូវដំណើរការការងារនានានៅក្នុងអាជីវកម្ម, ពង្រឹងគុណភាពផលិតផល ឬសេវាកម្ម, ពង្រឹងទំនាក់ទំនងក្នុងក្រុមហ៊ុន និងជាមួយអតិថិជន ក៏ដូចជាដៃគូអាជីវកម្ម និងបង្កើនប្រសិទ្ធភាពនៃការធ្វើទីផ្សារជាដើម។ ជាក់ស្តែង ឧបករណ៍ឆ្លាតក៏បានជួយសម្រួលដល់ដំណើរការអាជីវកម្ម ដោយបានផ្លាស់ប្តូរការធ្វើអាជីវកម្ម

តាមបែបប្រពៃណីមកជាការធ្វើអាជីវកម្មតាមបែបទំនើប តាមរយៈការធ្វើស្វ័យប្រវត្តិកម្មការងារ ព្រមទាំងការទទួល និងវិភាគទិន្នន័យនានា ដែលធ្វើឱ្យការធ្វើអាជីវកម្មកាន់តែមានស័ក្តិសិទ្ធភាព ផលិតភាព និងភាពប្រកួតប្រជែង។ ជាឧទាហរណ៍ យោងតាមគេហទំព័រ YourMobile នៅឆ្នាំ២០២០ **៨៥%** នៃអាជីវកម្មខ្នាតតូចបានប្រើប្រាស់ទូរស័ព្ទឆ្លាតដើម្បីបង្កើនផលិតភាពការងារនៅក្នុងអាជីវកម្មរបស់ពួកគេ។

## I. ឧបករណ៍ឆ្លាតដែលមានសក្តានុពលសម្រាប់អាជីវកម្ម

អាជីវកម្មតែងជួបប្រទះនូវបញ្ហានានាដែលអាចរាំងស្ទះដល់ដំណើរការការងារ ហេតុនេះហើយការប្រើប្រាស់ឧបករណ៍ឆ្លាតពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយសម្រួលដល់កិច្ចការងារនានារបស់ក្រុមហ៊ុនឱ្យកាន់តែមានស័ក្តិសិទ្ធភាព និងផលិតភាពបន្ថែមទៀត។ ខាងក្រោមនេះជាឧបករណ៍ឆ្លាតសំខាន់ៗមួយចំនួនសម្រាប់ជាជំនួយដល់ការធ្វើអាជីវកម្ម រួមមាន៖

- **ទូរស័ព្ទឆ្លាត (Smartphone)៖** ទូរស័ព្ទឆ្លាតសំដៅដល់ទូរស័ព្ទចល័ត ដែលអាចភ្ជាប់ទៅកាន់អ៊ីនធឺណិត និងមានបំពាក់នូវអេក្រង់ប៉ះ (Touch Screen) ព្រមទាំងអាចដំណើរការប្រព័ន្ធប្រតិបត្តិការ ដូចជា iOS, Android, Symbian និង BlackBerry OS ជាដើម។ នៅក្នុងការធ្វើអាជីវកម្ម ទូរស័ព្ទឆ្លាតអាចជួយឱ្យអាជីវកររក្សាទំនាក់ទំនងល្អជាមួយអតិថិជន និងដៃគូអាជីវកម្មទាំងក្នុង និងក្រៅប្រទេស តាមរយៈកម្មវិធីផ្ញើសារភ្លាមៗ (Instant Messaging App) មួយចំនួន ដូចជា WhatsApp, Messenger, WeChat, Telegram, Viber និងLine ក៏ដូចជាកម្មវិធីខលជាវីដេអូ ដូចជា Zoom, Google Meet និងMicrosoft Team។ មិនតែប៉ុណ្ណោះ ទូរស័ព្ទឆ្លាតក៏អាចជួយឱ្យអាជីវករប្រើប្រាស់បណ្តាញសង្គមបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ដើម្បីផ្សព្វផ្សាយ និងធ្វើទីផ្សារផលិតផល ឬសេវាកម្មនានា។ លើសពីនេះទៀត អាជីវករក៏អាចទាញយកនូវកម្មវិធីទូរស័ព្ទជាច្រើន ដែលអាចជួយបង្កើនផលិតភាពការងារ ដូចជា កម្មវិធី QuickBooks សម្រាប់សម្រួលដល់ដំណើរការគណនេយ្យ, កម្មវិធី Oracle CRM សម្រាប់រក្សាទិន្នន័យរបស់អតិថិជន និងវិភាគពីតម្រូវការរបស់ពួកគេ និងកម្មវិធី Teamdeck សម្រាប់រៀបចំកាលវិភាគ និងតាមដានដំណើរការការងារជាដើម។



**ឧបករណ៍អានកាតឆ្លាត (Smart Card Reader)៖** ឧបករណ៍អានកាតឆ្លាតជាឧបករណ៍ឆ្លាត ដែលមិនត្រឹមតែអាចអាន ឬបង្ហាញទិន្នន័យរបស់កាត តាមរយៈការឆូត ឬការដាក់ចូលឧបករណ៍អាន ប៉ុណ្ណោះទេ តែវាក៏មានភ្ជាប់អ៊ីនធឺណិត ដែលអាចអាន ឬបង្ហាញទិន្នន័យពីចម្ងាយ តាមរយៈការស្កេន ផងដែរ។ ឧបករណ៍អានកាតឆ្លាតនេះអាចជួយឱ្យអតិថិជនមានភាពងាយស្រួលក្នុងការទូទាត់ប្រាក់ ព្រោះ ពួកគេគ្រាន់តែធ្វើការស្កេនកាតឥណទាន (Credit Card) និងកាតឥណពន្ធ (Debit Card) លើឧបករណ៍ ឆ្លាតនេះ នោះការទូទាត់ប្រាក់នឹងដំណើរការដោយប្រើរយៈពេលប៉ុន្មានវិនាទីប៉ុណ្ណោះ ហើយដោយសារការ ទូទាត់នេះមានភាពរហ័ស វាក៏ធ្វើឱ្យជនខិលខូចមានការលំបាកក្នុងការលួចព័ត៌មានរបស់អតិថិជនផងដែរ។



**ម៉ាស៊ីនព្រីនឆ្លាត (Smart Printer)៖** ម៉ាស៊ីនព្រីនឆ្លាតអាចបំពេញមុខងារដូចម៉ាស៊ីនព្រីនធម្មតាដែរ ប៉ុន្តែវាមានបន្ថែមនូវមុខងារជាច្រើនទៀត ដែលអាចជួយសន្សំសំចៃថវិកា ព្រមទាំងផ្តល់នូវភាពងាយស្រួល និងសុវត្ថិភាពដល់អ្នកប្រើប្រាស់។ ជាក់ស្តែង ដោយសារម៉ាស៊ីនព្រីនឆ្លាតភ្ជាប់ទៅកាន់អ៊ីនធឺណិត វាអាច ឱ្យអាជីវករព្រីនឯកសារនានាបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង តាមរយៈទូរស័ព្ទ កុំព្យូទ័រ និងថេប្លេត។ មិនតែប៉ុណ្ណោះ ដើម្បីកាត់បន្ថយការព្រីនឯកសារខ្ជះខ្ជាយ ម៉ាស៊ីនព្រីនឆ្លាតក៏បានអនុញ្ញាតឱ្យក្រុមហ៊ុន កំណត់ចំនួនក្រដាសដែលបុគ្គលិកម្នាក់ៗអាចព្រីនក្នុងមួយសប្តាហ៍ ឬក្នុងមួយខែ។ លើសពីនេះទៀត យោងតាមគេហទំព័រ Impactmybiz នៅឆ្នាំ២០១៩ សហគ្រាសចំនួនប្រមាណ **៦០%** នៅប្រទេស អង់គ្លេស សហរដ្ឋអាមេរិក បារាំង និងអាល្លឺម៉ង់ បានរងគ្រោះពីការលួចចូល (Hack) ម៉ាស៊ីនព្រីនដោយ ជនខិលខូច ដែលធ្វើឱ្យសហគ្រាសបាត់បង់ទិន្នន័យសំខាន់ និងខាតបង់ប្រាក់ចំណូលជាមធ្យមប្រមាណ **៤សែនដុល្លារអាមេរិក**។ ក្នុងន័យនេះ ការប្រើប្រាស់ម៉ាស៊ីនព្រីនឆ្លាតពិតជាមានភាពចាំបាច់ណាស់ ក្នុងការរក្សាទិន្នន័យសម្ងាត់របស់ក្រុមហ៊ុនព្រោះបច្ចេកវិទ្យានេះអាចអ៊ីនគ្រីប (Encrypt) ទិន្នន័យ ហើយ ក៏អាចអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការកំណត់ឱ្យបុគ្គលិក Log in មុននឹងអាចចូលប្រើប្រាស់ម៉ាស៊ីនព្រីន ឆ្លាតនេះផងដែរ។



**ទែម៉ូស្តាតឆ្លាត (Smart Thermostat)**៖ ទែម៉ូស្តាតឆ្លាតជាឧបករណ៍ឆ្លាតដែលភ្ជាប់ទៅកាន់អ៊ីនធឺណិត ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការត្រួតពិនិត្យ និងកំណត់សីតុណ្ហភាពនៅក្នុង ការិយាល័យ តាមរយៈកម្មវិធីទូរស័ព្ទបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ក្រុមហ៊ុនអាចប្រើប្រាស់ទែម៉ូស្តាតឆ្លាតនេះ ដើម្បីបញ្ឈប់ដំណើរការម៉ាស៊ីនត្រជាក់ និងម៉ាស៊ីនកំដៅបានដោយស្វ័យប្រវត្តិនៅពេលមិនត្រូវការប្រើប្រាស់។ ការណ៍នេះ អាចជួយសន្សំសំចៃថាមពលអគ្គសនីបានច្រើន ដែលអាចឱ្យក្រុមហ៊ុនសន្សំសំចៃថវិកាបាន។ ជាក់ស្តែង បើយោងគេហទំព័រ Enercare នៅឆ្នាំ២០២០ ទែម៉ូស្តាតឆ្លាតអាចជួយសន្សំសំចៃថាមពលអគ្គិសនីចំពោះការប្រើប្រាស់ម៉ាស៊ីនត្រជាក់បានជាមធ្យមប្រមាណ **១១%** និងម៉ាស៊ីនកំដៅបានប្រមាណ **១៥%**។



**កាមេរ៉ាឆ្លាត (Smart Camera)៖** កាមេរ៉ាឆ្លាតសំដៅដល់កាមេរ៉ាដែលអាចថតនូវសកម្មភាពនានាបាន ហើយភ្ជាប់ទៅកាន់អ៊ីនធឺណិត ដើម្បីអាចបញ្ជូនវីដេអូសកម្មភាពទាំងនោះទៅកាន់កម្មវិធីទូរស័ព្ទ ឬកន្លែងផ្ទុកទិន្នន័យលើក្លោដ (Cloud Storage)។ ក្នុងន័យនេះ ការប្រើប្រាស់កាមេរ៉ាឆ្លាតអាចជួយឱ្យម្ចាស់អាជីវកម្មតាមដានពីដំណើរការអាជីវកម្មរបស់ខ្លួន និងការបំពេញការងាររបស់បុគ្គលិកបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ក្នុងពេលវេលាជាក់ស្តែង តាមរយៈទូរស័ព្ទដៃ។ មិនតែប៉ុណ្ណោះ កាមេរ៉ាឆ្លាតក៏អាចជួយកាត់បន្ថយការលួចទំនិញនៅក្នុងហាងផងដែរ ព្រោះកាមេរ៉ាឆ្លាតមួយចំនួនមានបំពាក់នូវប៊ូតុងស៊ីរ៉ែន (Siren  Button) ដើម្បីឱ្យសន្តិសុខចុចបន្លឺសំឡេងឡើងនៅពេលមានជនខិលខូចលួចទំនិញ ដែលអាចធ្វើឱ្យពួកគេមានការភ័យខ្លាចក្នុងការលួច។ លើសពីនេះទៀត កាមេរ៉ាឆ្លាតនេះក៏មានបំពាក់នូវមុខងារ Night Vision ដែលធ្វើឱ្យគុណភាពវីដេអូច្បាស់ បើទោះបីជានៅពេលយប់ក៏ដោយ ហើយក៏មានបំពាក់នូវសែនស័រ (Sensor) ដែលអាចផ្តល់ដំណឹងដល់ម្ចាស់អាជីវកម្ម តាមរយៈកម្មវិធីទូរស័ព្ទ នៅពេលមានជនខិលខូចលួចចូលហាងនៅពេលយប់ផងដែរ។



## II. អត្ថប្រយោជន៍ និងសារៈសំខាន់នៃឧបករណ៍ឆ្លាតសម្រាប់អាជីវកម្ម

ការរីកចម្រើននៃបច្ចេកវិទ្យា ពិសេសឧបករណ៍ឆ្លាត បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវរបៀបប្រាស្រ័យទាក់ទងគ្នារវាងអ្នកលក់ និងអ្នកទិញ របៀបផ្តល់សេវាកម្មដល់អតិថិជន និងរបៀបបំពេញការងាររបស់បុគ្គលិកជាដើម ដែលធ្វើឱ្យដំណើរការអាជីវកម្មកាន់តែមានស័ក្តិសិទ្ធភាព និងផលិតភាព។ ខាងក្រោមនេះជាអត្ថប្រយោជន៍ និងសារៈសំខាន់មួយចំនួនដែលឧបករណ៍ឆ្លាតផ្តល់ឱ្យអាជីវករ រួមមាន៖

**ជួយពង្រឹងការផ្តល់សេវាកម្មដល់អតិថិជន៖** បច្ចុប្បន្ននេះ ឧបករណ៍ឆ្លាតពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយពង្រឹងការផ្តល់សេវាកម្មដល់អតិថិជន ដែលធ្វើឱ្យក្រុមហ៊ុនកាន់តែមានភាពប្រកួតប្រជែង។ ជាក់ស្តែង អតិថិជនអាចធ្វើការសាកសួរព័ត៌មាន និងស្វែងរកជំនួយបាន ក្នុងពេលវេលាជាក់ស្តែង តាមរយៈកម្មវិធីផ្ញើសារភ្លាមៗ (Instant Messaging App) នៅលើទូរស័ព្ទឆ្លាត។ មិនតែប៉ុណ្ណោះ ការបង្កើតកម្មវិធីទូរស័ព្ទនៅលើទូរស័ព្ទឆ្លាតក៏អាចជួយឱ្យអតិថិជនមានភាពងាយស្រួលជាងមុនក្នុងការទិញនូវទំនិញ ឬសេវាកម្មនានា ព្រោះពួកគេមិនចាំបាច់ទៅទិញផ្ទាល់ដល់ហាង ដែលធ្វើឱ្យខ្ជះខ្ជាយពេលវេលាច្រើន ហើយក្រុមហ៊ុនក៏អាចជូនដំណឹងដល់អតិថិជនបានភ្លាមៗពីការបញ្ចុះតម្លៃ និងទំនិញមកដល់ថ្មី តាមរយៈកម្មវិធីទូរស័ព្ទនេះផងដែរ។

**ជួយបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ៖** វត្តមាននៃឧបករណ៍ឆ្លាតបានជួយសម្រួលយ៉ាងខ្លាំងដល់ការបំពេញការងាររបស់បុគ្គលិក។ ជាឧទាហរណ៍ តុការិយាល័យឆ្លាត (Smart Desk) មានបំពាក់នូវអេក្រង់ប៉ះ ដែលអាចឱ្យបុគ្គលិកធ្វើការស្កេនក្រដាស, សាកថ្មដោយឥតប្រើខ្សែ និងមានភ្ជាប់ជាមួយនឹងកាសឥតប្រើខ្សែ (Wireless Earbuds) ដែលអាចឱ្យបុគ្គលិកប្រើប្រាស់សម្រាប់កិច្ចប្រជុំនានាបាន ព្រមទាំងអនុញ្ញាតឱ្យបុគ្គលិកធ្វើការបញ្ជាម៉ាស៊ីនឆុងកាហ្វេ, ហៅតាក់ស៊ី និងបញ្ជាទិញអាហារផងដែរ។ លើសពីនេះទៀត បុគ្គលិកក៏អាចកំណត់កាលវិភាគលើតុការិយាល័យឆ្លាត និងផ្លាស់ប្តូរកម្ពស់តុសម្រាប់ឈរ ឬអង្គុយធ្វើការតាមតម្រូវការ ដែលអាចជួយបង្កើននូវផលិតភាពការងារផងដែរ។

**ជួយសម្រួលដល់ការធ្វើការងារពីចម្ងាយ៖** ឧបករណ៍ឆ្លាតបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ការធ្វើការងារពីចម្ងាយ។ ជាក់ស្តែង នាឡិកាឆ្លាត (Smart Watch) បានអនុញ្ញាតិឱ្យបុគ្គលិកធ្វើការកត់ចំណាំ, ទទួលបានការជូនដំណឹងភ្លាមៗនៅពេលមានអ៊ីម៉ែល និងសារថ្មីផ្ញើមក, កំណត់កាលវិភាគសម្រាប់ការណាត់ជួបនានា, ទូទាត់ប្រាក់ និងថតសំឡេងជាដើម។ ទន្ទឹមនឹងនេះ នាឡិកាឆ្លាតក៏អនុញ្ញាតឱ្យបុគ្គលិកធ្វើការតបសារ ធ្វើការហៅចេញ និងទទួលការហៅចូលពីអតិថិជនបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងផងដែរ។

**ជួយសន្សំសំចៃថវិកា៖** ឧបករណ៍ឆ្លាតពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនីខ្ជះខ្ជាយ ដែលអាចជួយសន្សំសំចៃថវិការបស់ក្រុមហ៊ុនបានច្រើន។ ជាឧទាហរណ៍ អំពូលភ្លើងឆ្លាតមានបំពាក់នូវសែនស័រចាប់សញ្ញាចលនា (Motion Sensor) ដែលអាចបើកភ្លើងដោយស្វ័យប្រវត្តិនៅពេលមានមនុស្សនៅក្នុងការិយាល័យ និងបិទទៅវិញដោយស្វ័យប្រវត្តិ

នៅពេលគ្មានមនុស្សនៅ ហើយអំពូលភ្លើងឆ្លាតនេះក៏អាចកែតម្រូវពន្លឺទៅតាមតម្រូវការជាក់ស្តែង ដែលអាចជួយសន្សំសំចៃថាមពលអគ្គិសនីបានច្រើន។ មិនតែប៉ុណ្ណោះ យោងតាមគេហទំព័រ Hive អំពូលភ្លើងឆ្លាតអាចប្រើប្រាស់បានយូរជាងអំពូលភ្លើងធម្មតារហូតដល់ **១៥ដង** ដែលអាចជួយសន្សំសំចៃថវិកាបានយ៉ាងច្រើនដល់ក្រុមហ៊ុន។

**ជួយរក្សាសុវត្ថិភាព៖** ឧបករណ៍ឆ្លាតក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាសុវត្ថិភាពកន្លែងប្រកបអាជីវកម្ម។ ជាក់ស្តែង យោងតាមគេហទំព័រ KGW8 នៅឆ្នាំ២០២២ នេះ អាជីវកម្មនៅទីក្រុង Portland នៃសហរដ្ឋអាមេរិក ចំនួនប្រមាណ **៦៣%** បានរងគ្រោះដោយសារចោរលួច។ ហេតុនេះហើយ ការប្រើប្រាស់ឧបករណ៍រោទ៍ឆ្លាត (Smart Alarm Kit) ដូចជា Amalock Alarm Kit, ERA Protect Base Smart Alarm System, Yale Smart App Alarm Kit ជាដើម ពិតជាមានសារៈសំខាន់ណាស់ ព្រោះឧបករណ៍នេះមានបំពាក់នូវសែនស័រ ដែលអាចចាប់សញ្ញាបាននៅពេលមានជនខិលខូចលួចចូលក្នុងកន្លែងប្រកបអាជីវកម្ម ហើយឧបករណ៍ឆ្លាតនេះនឹងជូនដំណឹងដល់ម្ចាស់អាជីវកម្ម និងក្រុមប៉ូលីសតាមរយៈសារ, អ៊ីម៉ែល ឬកម្មវិធីទូរស័ព្ទ។ មិនតែប៉ុណ្ណោះ ឧបករណ៍រោទ៍ឆ្លាតមួយចំនួនក៏មានបំពាក់នូវស៊ីរ៉ែន (Siren) ដោយអាចបន្លឺសំឡេងខ្លាំងនៅពេលមានជនខិលខូចលួចចូលក្រុមហ៊ុន ដែលអាចធ្វើឱ្យជនខិលខូចទាំងនោះមានការភ័យខ្លាច។

## III. សន្និដ្ឋាន

ជារួម ការរីកចម្រើននៃបច្ចេកវិទ្យាបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវរបៀបដែលមនុស្សរស់នៅ ការបំពេញការងារ ការធ្វើអាជីវកម្ម ការសិក្សារៀនសូត្រ និងការទំនាក់ទំនងគ្នាជាដើម។ ជាក់ស្តែង វត្តមាននៃឧបករណ៍ឆ្លាតបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវដំណើរការអាជីវកម្ម ដោយបានជួយអាជីវករក្នុងការពង្រឹងការផ្តល់សេវាកម្មដល់អតិថិជន, ជួយបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ, ជួយសម្រួលដល់ការធ្វើការងារពីចម្ងាយ, ជួយសន្សំសំចៃថវិកា និងជួយរក្សាសុវត្ថិភាពកន្លែងប្រកបអាជីវកម្មផងដែរ។ ដូច្នេះ សហគ្រិនដែលជាម្ចាស់អាជីវកម្ម ទាំងខ្នាតតូច និងខ្នាតធំ គួរចេះទាញយកសក្តានុពលពីការប្រើប្រាស់ឧបករណ៍ឆ្លាត ដើម្បីអាចរក្សាបាននូវភាពប្រកួតប្រជែងក្នុងទីផ្សារបច្ចុប្បន្ន ហើយអាជីវករក៏គួរប្រើប្រាស់ឧបករណ៍ឆ្លាតទាំងនេះឱ្យចំទិសដៅ ស្របទៅតាមតម្រូវការជាក់ស្តែង ដើម្បីអាចទាញយកផលប្រយោជន៍ជាអតិបរមាបាន។

## ឯកសារយោង


- *Mobile technology for small businesses*, ចេញផ្សាយថ្ងៃទី ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០២០, ចូលអានថ្ងៃទី ២៦ ខែមិថុនាឆ្នាំ២០២២, https://yourmobile.com/mobile-technology-for-small-businesses/#:~:text=According%20to%20recent%20research%20from,their%20smartphone%20to%20check%20email
- *Advantages of Using Smartphones in Your Business*, ចេញផ្សាយថ្ងៃទី ថ្ងៃទី ១៣ មករា ២០១៣, ចូលអានថ្ងៃទី ២៦ ខែមិថុនាឆ្នាំ២០២២, https://www.business2community.com/tech-gadgets/advantages-of-using-smartphones-in-your-business-0375741
- *How Do Smart Card Readers Work?* , ចេញផ្សាយថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០២០, ចូលអានថ្ងៃទី ២៧ ខែមិថុនាឆ្នាំ២០២២, https://blog.nortechcontrol.com/how-smart-card-readers-work#:~:text=A%20smart%20card%20reader%20is%20a%20hardware%20device%20required%20to,or%20contactless%20via%20Wi-Fi
- *4 measurable benefits to 'smart printers'*, ចូលអានថ្ងៃទី ២៧ ខែមិថុនាឆ្នាំ២០២២,https://www.futurelogic.com.au/4-measureable-benefits-smart-printers/
- *Printer Security: Why It Matters to SMBs*, ចេញផ្សាយថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២២, ចូលអានថ្ងៃទី ២៧ ខែមិថុនាឆ្នាំ២០២២, https://www.impactmybiz.com/blog/blog-printer-security-why-it-matters-to-smbs/
- *6 Features to Look for in a Smart Thermostat*, ចេញផ្សាយថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០១៧, ចូលអានថ្ងៃទី ២៨ ខែមិថុនាឆ្នាំ២០២២, https://berkeleyheating.com/article/6-features-look-smart-thermostat
- *How Do Smart Cameras Work?*, ចេញផ្សាយថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១៩, ចូលអានថ្ងៃទី ២៨ ខែមិថុនាឆ្នាំ២០២២, https://www.technology.org/2019/07/18/how-do-smart-cameras-work/
- *7 Reasons Why Your Business Needs a Mobile App?*, ចូលអានថ្ងៃទី ២៨ ខែមិថុនាឆ្នាំ២០២២, https://www.allbusiness.com/7-reasons-business-needs-mobile-app-19179-1.html
- *How to save money with smart lights?* , ចូលអានថ្ងៃទី ២៩ ខែមិថុនាឆ្នាំ២០២២, https://www.hivehome.com/discover-hive/smart-lighting/why-smart-lights-are-a-solid-investment
- *How to Increase Your Productivity with Wearables While Working From Home (WFH) ?*, ចេញផ្សាយថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២១, ចូលអានថ្ងៃទី ២៩ ខែមិថុនាឆ្នាំ២០២២, https://ambiq.com/how-to-increase-your-productivity-with-wearables-while-working-from-home-wfh/#:~:text=More%20Efficient&text=For%20example%2C%20wearables%20with%20voice,can%20help%20you%20save%20time
- *This futuristic $4,000 'smart desk' can manage your entire work life — here's what it can do*, ចេញផ្សាយថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០១៨, ចូលអានថ្ងៃទី ៣០ ខែមិថុនាឆ្នាំ២០២២, https://www.businessinsider.com/cemtrex-smart-desk-features-controls-cost-2018-6

- *Survey: 63% of Portland businesses report break-ins or vandalism*, ចេញផ្សាយថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០២២, ចូលអានថ្ងៃទី ៣០ ខែមិថុនាឆ្នាំ២០២២, *https://www.kgw.com/article/money/business/survey-portland-businesses-break-ins-vandalism/283-1f1d2229-20ad-42a4-bd5d-58c24143daba*

---


www.cambodia4point0.org

កម្ពុជា ៤.០ - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.០ Cambodia 4.0

កម្ពុជា ៤.០ - Cambodia 4.0

កម្ពុជា ៤.០ - Cambodia 4.0

កម្ពុជា ៤.០ - Cambodia 4.0

Cambodia 4.0 Center